# សេចក្តីប្រកាស South2South
## របៀបប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញឲ្យមានសេរីភាព ក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ក្នុងប្រទេសកំពុងអភិវឌ្ឍ

## អំពីសេចក្តីប្រកាស

សេចក្តីប្រកាស South2South ត្រូវបានបង្កើតឡើងក្នុងកំឡុងកិច្ចពិភាក្សាប្រព័ន្ធផ្សព្វផ្សាយមួយដែលមានរយៈពេល៤ថ្ងៃ ហើយដែលបានផ្តោតលើការស្វែងរកវិធីសាស្ត្រក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញឲ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មានក្នុងប្រទេសកំពុងអភិវឌ្ឍ។

កិច្ចពិភាក្សាពីប្រព័ន្ធផ្សព្វផ្សាយនេះសហការរៀបចំដោយ DW Akademie (អាល្លឺម៉ង់) និង IAJ (អាហ្វ្រិកខាងត្បូង) ហើយប្រមូលផ្តុំ អ្នកសារព័ត៌មាន សកម្មជន និងអ្នកជំនាញអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយមកពីប្រទេសចំនួន១៤ ដើម្បីឲ្យពួកគេផ្លាស់ប្តូរចំនេះដឹង និងគំនិត។

ឆ្លងកាត់ការពិភាក្សា និងសកម្មភាពបង្កើតគំនិតមួយចំនួន ប្រតិភូទាំង១៤រូប បានបង្កើតគោលការណ៍ស្នូលចំនួន៧ ដើម្បីជំរុញឲ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ គោលការណ៍នីមួយៗមានអនុសាសន៍ដើម្បីឲ្យបុគ្គល និងស្ថាប័នគិតគូរពេលដែលពួកគេប្រើបច្ចេកវិទ្យាឌីជីថលដើម្បីជំរុញឲ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងសារពត៌មាន។

## សេចក្តីប្រកាស

South2South លើកស្ទួយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញឲ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ដែលជាសិទ្ធិមូលដ្ឋានមានចែងនៅក្នុងមាត្រាទី១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ។

សេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេសកំពុងអភិវឌ្ឍជួបប្រទះនឹងឧបសគ្គជាច្រើន ដូចជា របបដឹកនាំផ្តាច់ការ ការរំលោភសិទ្ធិមនុស្ស វិសមភាព ភាពក្រីក្រ អំពើពុករលួយ ការត្រូវគេតាមដាន និងឃ្លាំមើល កង្វះលទ្ធភាពទទួលព័ត៌មាន អនក្ខរកម្ម ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទន់ខ្សោយ សេវាអ៊ីនធើណិតទន់ខ្សោយ និងសេវាទំនាក់ទំនងមានតម្លៃខ្ពស់ ។ ក៏ប៉ុន្តែ ពួកយើងជឿថា ប្រទេសកំពុងអភិវឌ្ឍអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ប្រកបដោយភាពច្នៃប្រឌិត ក្រមសីលធម៌ ប្រជាធិបតេយ្យ ការរួបរួម និងការសហការរវាងគ្នាដើម្បីដោះស្រាយបញ្ហា និងធ្វើឲ្យជីវិតរស់នៅកាន់តែប្រសើរឡើង។

យើងជឿជាក់យ៉ាងមុតមាំថា ដើម្បីជំរុញអោយមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន មន្ត្រីរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងស្ថាប័នផ្សេងៗទៀត គួរពិនិត្យមើលគោលការណ៍ South2South ក្នុងពេលរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោងទាំងឡាយ ដែលប្រើបច្ចេកវិទ្យាឌីជីថល។

សេចក្តីប្រកាសនេះ ត្រូវបានសម្រេចបង្កើតឡើងក្នុងកិច្ចពិភាក្សាប្រព័ន្ធផ្សព្វផ្សាយ South2South ដែលត្រូវបានធ្វើឡើង នៅទីក្រុងខេបថោន កាលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដែលសហការរៀបចំដោយស្ថាប័ន DW Akademie និង IAJ ។

ស្ថាបនិក សូមស្នើឲ្យអ្នកប្រើប្រាស់សេចក្តីប្រកាស South2South ទាំងអស់ជួយផ្សព្វផ្សាយសេចក្តីប្រកាសនេះបន្ត ហើយចូលរួមធ្វើឲ្យសេចក្តីប្រកាសនេះមានការវិវត្តទៅមុខ ។

# ១. យុទ្ធសាស្ត្រ

បង្កើតយុទ្ធសាស្ត្ររយៈពេលវែងដើម្បីបង្កើត និងរក្សាឲ្យបាននូវសេរីភាពក្នុងការបញ្ចេញមតិ

អនុសាសន៍៖

- វិភាគពីស្ថានភាពសេរីភាពក្នុងការបញ្ចេញមតិ និងការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច
- បង្កើតដៃគូ និងបណ្តាញនានាក្នុងការគាំទ្រដល់សេរីភាពក្នុងការបញ្ចេញមតិ
- ប្រើប្រាស់បទដ្ឋានត្រឹមត្រូវ និងជាក់លាក់ ដើម្បីរៀបចំ អភិវឌ្ឍ និង វាយតម្លៃគម្រោង
- អភិវឌ្ឍ និងកែសម្រួលបច្ចេកវិទ្យាឌីជីថល ដើម្បីអោយស្របទៅនឹងបម្រែបម្រួលស្ថានការណ៍ ឬតម្រូវការជាក់ស្តែង
- រក្សាតម្លាភាពទាក់ទងនឹងប្រភព និងលក្ខខណ្ឌប្រើប្រាស់ថវិកាទ្រទ្រង់គម្រោង

# ២. ការរួមបញ្ចូលគ្នា

រួមបញ្ចូលគ្នារវាងបច្ចេកវិទ្យាឌីជីថល និងមធ្យោបាយទាក់ទងដែលមានស្រាប់ ដើម្បីជំរុញឲ្យមានសេរីភាព ក្នុងការបញ្ចេញមតិ

អនុសាសន៍៖

- ផ្តល់តម្លៃលើទម្រង់នៃការពិភាក្សារបស់សហគមន៍ និងមធ្យោបាយផ្សព្វផ្សាយដែលមានស្រាប់ និងដាក់បញ្ចូលទម្រង់ទាំងនោះទៅក្នុងគម្រោងឌីជីថល
- ផ្គត់ផ្គង់សហគមន៍ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលពួកគេអាចប្រើបាន និងមានតម្លៃសមរម្យ
- គោរពតាមគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិស្មើគ្នាក្នុងការបញ្ចេញមតិ
- ផ្តល់មធ្យោបាយសម្រាប់ទទួលបានប្រព័ន្ធផ្សព្វផ្សាយឲ្យបានស្មើៗគ្នា៖ “គិតពីអ្នកក្រោយគេឲ្យបានមុនគេ”
- គោរពភាពឯកជនរបស់បុគ្គលនីមួយៗ និងដាក់សន្តិសុខឌីជីថលជាអាទិភាព

# ៣. និរន្តរភាព

ប្រើប្រាស់មធ្យោបាយថ្មីៗ និងប្លែកៗ ដើម្បីឲ្យគម្រោងទាំងឡាយមាននិរន្តរភាព និងឯករាជ្យ

អនុសាសន៍៖

- ខិតខំឲ្យមានភាពជាម្ចាស់លើគម្រោងរួមគ្នា និងចំរុះសាវតារ
- ស្វែងរកដៃគូ និងប្រភពថវិកាទ្រទ្រង់ ដោយមិនប៉ះពាល់ដល់ឯករាជ្យភាពនៃគម្រោង

- សាកល្បងប្រើប្រាស់វិធីទ្រទ្រង់គម្រោងផ្សេងៗគ្នា ដើម្បីអាចបន្តគម្រោងបាន ក្រោយពី ថវិកាទ្រទ្រង់ពីខាងក្រៅត្រូវបានបញ្ចប់
- គិតពីការរកប្រាក់ចំណូលតាំងពីការចាប់ផ្តើមគម្រោង
- ប្រើប្រាស់កម្មវិធីកូដចំហ ឧបករណ៍កូដចំហ ដោយឥតគិតថ្លៃ និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អ្នកប្រើប្រាស់អ៊ីនធើណិត ដើម្បីជួយអោយការចំណាយមានប្រសិទ្ធិភាព

# ៤. ភាពបើកចំហ

ជួយអោយមហាជនទាំងអស់គ្នា យល់ដឹងអំពីសិទ្ធិទទួលព័ត៌មានឲ្យបានពេញលេញ

អនុសាសន៍៖

- បញ្ចេញមតិគាំទ្រសេរីភាពសារពត៌មាន និងច្បាប់ទាក់ទងនឹងតម្លាភាព
- បង្កើតបទដ្ឋានបើកចំហ
- ផ្តល់មធ្យោបាយប្រើប្រាស់បច្ចេកវិទ្យាទៅមនុស្សគ្រប់គ្នា
- បង្កើនការយល់ដឹងដល់ប្រជាជនទាក់ទងនឹងការប្រើប្រាស់ទិន្នន័យ តាមរយៈយុទ្ធនាការ និងវគ្គបណ្តុះបណ្តាល ទាំងនៅលើ និងក្រៅបណ្តាញអ៊ីនធើណិត
- ចែករំលែកព័ត៌មានឌីជីថលជាទម្រង់ឯកសារដែលងាយស្រួលប្រើប្រាស់

# ៥. ទិន្នន័យសម្រាប់ជាប្រយោជន៍ដល់មហាជន

ស្នើសុំ រៀបចំ វិភាគ និង ចែករំលែកទិន្នន័យ អោយមនុស្សគ្រប់គ្នាប្រើបាន ហើយភ្ជាប់អ្នកប្រើប្រាស់ទៅនឹងព័ត៌មានដែលពួកគេចង់បាន

អនុសាសន៍៖

- សម្រួល ពន្យល់ និងធ្វើទស្សនីយកម្មទិន្នន័យដើម្បីឲ្យងាយស្រួលយល់
- បង្កើត ផ្សព្វផ្សាយ ចែកចាយ និង ចែករំលែកសាច់រឿងដែលទាក់ទងនឹងទិន្នន័យដែលប្រមូលបាន
- ដាក់សំណុំទិន្នន័យដើម្បីឲ្យវត្ថុឌីជីថលទាំងអស់ងាយស្រួលរក ប្រើប្រាស់ និងបម្លែង
- ចេះច្នៃប្រឌិត និងប្រើមជ្ឈដ្ឋានចំរុះដើម្បីធ្វើទស្សនីយកម្ម ផ្សព្វផ្សាយ និងចែករំលែកទិន្នន័យ
- បង្កើតមធ្យោបាយល្អបំផុតក្នុងការស្វែងរកប្រភព រៀបចំ និងវិភាគទិន្នន័យ

# ៦. ការចូលរួម

ប្រើប្រាស់វិធីដែលអាចនាំឲ្យមានការចូលរួម (ពីអ្នកនៅក្នុងសហគមន៍) ដើម្បីពង្រឹងសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

អនុសាសន៍ ៖

- គិតគូរពីសហគមន៍ និងអ្នកទទួលព័ត៌មានគោលដៅ នៅពេលរៀបចំ អភិវឌ្ឍ អនុវត្ត និងវាយតម្លៃ គម្រោង
- ធ្វើអោយប្រាកដថា មជ្ឈដ្ឋានដែលចូលរួម ត្រូវមានសុវត្ថិភាព និងគាំទ្រអោយមានការបញ្ចេញមតិ ដោយបើកចំហ
- ប្រើប្រាស់ឧបករណ៍ វិធីសាស្ត្រ និងវេទិការបស់គេហទំព័រ ដែលមានស្រាប់ដើម្បីជំរុញឲ្យមានការចូលរួម

- អប់រំផ្នែកអក្ខរកម្មឌីជីថល ដើម្បីឲ្យសហគមន៍មានលទ្ធភាពចូលរួមកាន់តែច្រើនឡើង
- គាំទ្រសិទ្ធិក្នុងការបង្កើតវេទិកាឌីជីថលដោយខ្លួនឯង។ ទាក់ទាញ និងដាស់ស្មារតីអ្នកនយោបាយ និងមន្ត្រីសាធារណៈឲ្យទទួលស្គាល់កាតព្វកិច្ច និងគណនេយ្យភាពរបស់ពួកគេក្នុងសហគមន៍របស់ខ្លួន

## ៧. ការចែករំលែកជំនាញ

ចែករំលែកចំនេះដឹង និងបទពិសោធន៍ក្នុងបណ្តាអ្នកអនុវត្តគម្រោងឌីជីថលទាំងអស់

អនុសាសន៍៖

- ប្រើប្រាស់វិធីសាស្ត្រ និងវេទិកាចម្រុះដើម្បីចែករំលែកចំនេះដឹង និងជំនាញ
- គាំទ្រការចែករំលែកចំនេះដឹង និងជំនាញទាំងនៅលើ និងក្រៅបណ្តាញអ៊ីនធើណិត
- សាកល្បងបង្កើតវេទិកាសម្រាប់ចែករំលែកសៀវភៅអេឡិចត្រូនិច អត្ថបទស្រាវជ្រាវ និងកម្មវិធី  កូដចំហ
- បង្កើតធនាគារឌីជីថលមួយសម្រាប់ផ្ទុក និងដោះដូរឯកសារទិន្នន័យចំហ
- ចែករំលែកបញ្ជីទំនាក់ទំនងស្ថាប័នផ្សព្វផ្សាយ
- បង្ហាត់អ្នករួមការងារតាមវេទិកាលើបណ្តាញអ៊ីនធើណិត
- រៀបចំសកម្មភាពក្រៅបណ្តាញអ៊ីនធើណិត ដូចជា សិក្ខាសាលា និងព្រឹត្តិការណ៍នៅសាកលវិទ្យាល័យ និងសាលា ហើយចែករំលែកលទ្ធផលលើបណ្តាញអ៊ីនធើណិត
- ផ្តល់ដំណឹង  និងអប់រំមហាជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានហើយដូចជា  ទូរទស្សន៍  វិទ្យុ  និងកាសែត

## ការប្តេជ្ញាចិត្ត

ស្ថាបនិកហត្ថលេខីខាងក្រោម ប្តេជ្ញាចិត្តគោរពតាម សេចក្តីប្រកាស South2South នេះ និងជំរុញ លើកទឹកចិត្តឲ្យអ្នកដទៃធ្វើតាមគោលការណ៍នៃសេចក្តីប្រកាសនេះ។ សេចក្តីប្រកាសនេះ បើកទូលាយឲ្យមានការពិភាក្សា។ សូមផ្តល់យោបល់ខាងក្រោម ឬជួយ ត្រួតពិនិត្យសេចក្តីប្រកាសនេះក្នុងឯកសាររបស់យើង។

Ahmad Al-Bazz
Editor, Dooz, Palestinian Territories

Penhleak ( Pinkie ) Chan
Managing Editor, Open Development Cambodia, Cambodia

Shubhransu Choudhary
Founder, CGNet Swara, India

Guy Degen
DW Akademie

Wouter Dijkstra
Founder and Director, TRAC FM, Uganda

Noora Flinkman
Head of Marketing and Communications Unit, HarassMap, Egypt

Alejandra Gutiérrez Valdizán
Editor-in-Chief, Plaza Pública, Guatemala

Kate Hairsine
DW Akademie

Bektour Iskender
Founder, Kloop, Kyrgyz Republic

Toufique Imrose Khalidi
Editor-in-Chief and Managing Director, bdnews24.com, Bangladesh

Fiona Macleod
Founder and Editor, Oxpeckers Center for Investigative Environmental Journalism, South Africa

Steffen Leidel
DW Akademie

Nigel Mugamu
Founder and CEO, 263Chat, Zimbabwe

Dickens Olewe
Founder of AfricanSkyCAM and Knight Journalism Fellow at Stanford University, Kenya & USA

Oscar Parra Castellanos
Founder and Editor, Rutas del Conflicto, Colombia

Angelica (Momi) Peralta Ramos
Multimedia Development Manager and Project Manager of La Nación Data, La Nación, Argentina

Fabiola Torres Lopéz
Co-Founder and Reporter, Ojo Público, Peru

ខែធ្នូ ឆ្នាំ២០១៤